តារាងខាងក្រោមបង្ហាញពីភាពអាចរកបាននៃទ្រព្យសកម្មហិរញ្ញវត្ថុរបស់សាខាធនាគារ ដើម្បីគាំទ្រដល់មូលនិធិនាពេលអនាគត។ (ត)

| | បានដាក់បន្ទុក | | មិនបានដាក់បន្ទុក | | | |
|---|---|---|---|---|---|---|
| | ដែលបានដាក់ជាទ្រព្យបញ្ចាំ | ផ្សេងៗ(*) | ដែលមានហើយអាចដាក់ជាទ្រព្យបញ្ចាំ | ផ្សេងៗ(**) | សរុប | |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់ក្នុងដៃ | - | - | - | 6,290,805 | 6,290,805 | 25,628,740 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 35,198,822 | 9,000,000 | | 73,855,674 | 118,054,496 | 480,954,017 |
| សមតុល្យនៅធនាគារនានា | - | - | - | 8,504,128 | 8,504,128 | 34,645,817 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា | - | - | - | 79,850,543 | 79,850,543 | 325,311,112 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | - | - | - | 331,271,286 | 331,271,286 | 1,349,599,219 |
| ទ្រព្យសកម្មផ្សេងៗ | - | - | - | 273,410 | 273,410 | 1,113,872 |
| | 35,198,822 | 9,000,000 | - | 500,045,846 | 544,244,668 | 2,217,252,777 |

(*) សំដៅទៅលើទ្រព្យសកម្មដែលមិនត្រូវបានដាក់បញ្ចាំ ប៉ុន្តែសាខាធនាគារជឿជាក់ថា វាត្រូវបានដាក់កំហិតមិនឲ្យប្រើប្រាស់ដើម្បីទទួលបានមូលនិធិសម្រាប់ហេតុផលស្របច្បាប់ ឬហេតុផលផ្សេងទៀត។

(**) សំដៅទៅលើទ្រព្យសកម្មដែលមិនមានដាក់កំហិតអាចប្រើប្រាស់ជាទ្រព្យបញ្ចាំបាន ប៉ុន្តែសាខាធនាគារ មិនរំពឹងថាអាចប្រើបានភ្លាមៗដើម្បីទទួលបានមូលនិធិនៅក្នុងដំណើរការ អាជីវកម្មធម្មតានោះទេ។

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## ឃ. ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ គឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ - ឧទាហរណ៍ អត្រាការប្រាក់ អត្រាប្តូរប្រាក់បរទេស និងតម្លៃមូលបត្រ - នឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់សាខាធនាគារ ឬតម្លៃនៃការកាន់កាប់នូវឧបករណ៍ហិរញ្ញវត្ថុ។ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រង និងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ខណៈពេលដែលមានការបង្កើននូវ ប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញជាអតិបរមា។

### *(i). ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់ សំដៅលើការខាតបង់នូវចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់ និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ហានិភ័យអត្រាការប្រាក់ ត្រូវបានចាត់ចែងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើចំណូលនៃការបណ្តាក់ទុន តម្លៃទីផ្សារ និងថ្លៃដើមនៃមូលនិធិ។ សក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលអត្រាការប្រាក់ដែលខុសប្រក្រតី ត្រូវបានត្រួតពិនិត្យ ដោយធៀបទៅនឹងកម្រិតដែលអាចទទួលយកបាននៃហានិភ័យ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(i). ហានិភ័យអត្រាការប្រាក់ (ត)*

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់សាខាធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។

| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | តម្លៃយោង | រហូតដល់ 1ខែ | >1 ដល់ 3ខែ | >3 ដល់ 6ខែ | >6 ដល់ 12ខែ | >1 ដល់ 5ឆ្នាំ | លើសពី 5ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6,134,930 | - | - | - | - | - | - | 6,134,930 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 116,739,256 | 3,175,775 | 8,449,019 | 11,291,640 | 12,174,333 | - | - | 81,648,489 |
| សមតុល្យនៅធនាគារនានា | 9,371,470 | - | - | - | - | - | - | 9,371,470 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់ | | | | | | | | |
| គ្រឹះស្ថានហិរញ្ញវត្ថុនានា | 76,415,768 | - | 728,320 | 2,392,996 | 1,938,224 | 71,356,228 | - | - |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | 364,221,890 | 9,053,527 | 12,702,314 | 23,529,778 | 51,862,797 | 100,797,947 | 166,275,527 | - |
| មូលបត្រវិនិយោគ | 6,021,552 | - | - | - | 976,336 | 5,045,216 | - | - |
| ទ្រព្យសកម្មផ្សេងៗ | 256,227 | - | - | - | - | - | - | 256,227 |
| | 579,161,093 | 12,229,302 | 21,879,653 | 37,214,414 | 66,951,690 | 177,199,391 | 166,275,527 | 97,411,116 |

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(i). ហានិភ័យអត្រាការប្រាក់ (ត)*

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់សាខាធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។ (ត)

| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | តម្លៃយោង | រហូតដល់ 1ខែ | >1 ដល់ 3ខែ | >3 ដល់ 6ខែ | >6 ដល់ 12ខែ | >1 ដល់ 5ឆ្នាំ | លើសពី 5ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា | 84,997,557 | 30,742,474 | 53,243,014 | - | - | - | - | 1,012,069 |
| ប្រាក់បញ្ញើរបស់អតិថិជន | 81,137,189 | 67,706,732 | 11,250 | 300,951 | 4,214,335 | - | - | 8,903,921 |
| ប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល | 262,085,649 | 149,140,594 | 98,315,598 | - | - | 14,629,457 | - | - |
| ប្រាក់កម្ចី | 32,538,043 | 3,116,929 | 6,446,990 | 11,066,423 | 11,907,701 | - | - | - |
| បំណុលភតិសន្យា | 2,209,818 | 52,004 | 104,208 | 156,812 | 297,337 | 1,379,118 | 220,339 | - |
| បំណុលផ្សេងៗ | 707,120 | - | - | - | - | - | - | 707,120 |
| | 463,675,376 | 250,758,733 | 158,121,060 | 11,524,186 | 16,419,373 | 16,008,575 | 220,339 | 10,623,110 |
| សរុបគំលាតការប្រាក់ | 115,485,717 | (238,529,431) | (136,241,407) | 25,690,228 | 50,532,317 | 161,190,816 | 166,055,188 | 86,788,006 |
| ពាន់រៀល (កំណត់សម្គាល់ 5) | 475,454,697 | (982,025,668) | (560,905,873) | 105,766,669 | 208,041,549 | 663,622,590 | 683,649,210 | 357,306,221 |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(i). ហានិភ័យអត្រាការប្រាក់ (ត)*

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់សាខាធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។ (ត)

| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | តម្លៃយោង | រហូតដល់ 1ខែ | >1 ដល់ 3ខែ | >3 ដល់ 6ខែ | >6 ដល់ 12ខែ | >1 ដល់ 5ឆ្នាំ | លើសពី 5ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6,290,805 | - | - | - | - | - | - | 6,290,805 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 118,054,496 | 50,004 | 20,667,196 | 10,531,285 | 7,115,460 | - | - | 79,690,551 |
| សមតុល្យនៅធនាគារនានា | 8,504,128 | 8,504,128 | - | - | - | - | - | - |
| ឥណទាន និងបុរេប្រទានផ្តល់ដល់ គ្រឹះស្ថានហិរញ្ញវត្ថុនានា | 79,850,543 | - | - | 1,474,938 | 9,979,073 | 68,396,532 | - | - |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | 331,271,286 | 12,260,787 | 9,806,174 | 21,548,734 | 54,464,737 | 103,610,803 | 129,580,051 | - |
| ទ្រព្យសកម្មផ្សេងៗ | 273,410 | - | - | - | - | - | - | 273,410 |
| | 544,244,668 | 20,814,919 | 30,473,370 | 33,554,957 | 71,559,270 | 172,007,335 | 129,580,051 | 86,254,766 |

# ធនាគារ មេហ្គា អ៊ិនធើណេសិនណាល ខមមើសល សាខាភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(i). ហានិភ័យអត្រាការប្រាក់ (ត)*

តារាងខាងក្រោមនេះសង្ខេបពីហានិភ័យអត្រាការប្រាក់របស់សាខាធនាគារ។ តារាងនេះចង្អុលបង្ហាញពីរយៈពេលដែលឧបករណ៍ហិរញ្ញវត្ថុកំណត់ថ្លៃឡើងវិញ ឬមានកាលកំណត់ណាមួយណាដែលកើតឡើងមុន។ (ត)

| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | តម្លៃយោង | រហូតដល់ 1ខែ | >1 ដល់ 3ខែ | >3 ដល់ 6ខែ | >6 ដល់ 12ខែ | >1 ដល់ 5ឆ្នាំ | លើសពី 5ឆ្នាំ | ពុំមានការប្រាក់ |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | | |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា | 97,422,820 | 16,589,252 | 65,040,886 | 15,012,458 | - | - | - | 780,224 |
| ប្រាក់បញ្ញើរបស់អតិថិជន | 83,134,237 | 72,333,174 | - | 47,717 | 4,001,973 | - | - | 6,751,373 |
| ប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល | 200,857,856 | 85,252,455 | 43,062,406 | 53,036,086 | - | 19,506,909 | - | - |
| ប្រាក់កម្ចី | 35,953,069 | 24,765 | 18,100,859 | 10,353,146 | 7,474,299 | - | - | - |
| បំណុលភតិសន្យា | 2,493,074 | 49,029 | 98,245 | 147,836 | 297,370 | 1,767,868 | 132,726 | - |
| បំណុលផ្សេងៗ | 979,360 | - | - | - | - | - | - | 979,360 |
| | 420,840,416 | 174,248,675 | 126,302,396 | 78,597,243 | 11,773,642 | 21,274,777 | 132,726 | 8,510,957 |
| សរុបគំលាតការប្រាក់ | 123,404,252 | (153,433,756) | (95,829,026) | (45,042,286) | 59,785,628 | 150,732,558 | 129,447,325 | 77,743,809 |
| ពាន់រៀល (កំណត់សម្គាល់ 5) | 502,748,923 | (625,089,122) | (390,407,452) | (183,502,273) | 243,566,648 | 614,084,441 | 527,368,403 | 316,728,278 |

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(i). ហានិភ័យអត្រាការប្រាក់ (ត)*

សាខាធនាគារមិនមានបំណុលដែលមានអត្រាថេរក្នុងតម្លៃសមស្រួបតាមចំណេញ ឬខាតឡើយ ហើយ សាខាធនាគារក៏មិនមានឧបករណ៍និស្សន្ទនាចុងកាលបរិច្ឆេទទេ។ ដូច្នេះ ការផ្លាស់ប្តូរអត្រាការប្រាក់នៅកាលបរិច្ឆេទរាយការណ៍នឹងមិនប៉ះពាល់ដល់ចំណេញ ឬខាតឡើយ។ សាខាធនាគារមិនមានឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាប្រែប្រួលទេ។ ដូច្នេះ មិនមានការវិភាគរំញោចនៃលំហូរទឹកប្រាក់ត្រូវបានរៀបចំទេ។

*(ii). ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស*

ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួលបណ្តាល មកពីការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។

**ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ**

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណមានដូចខាងក្រោម៖

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ប្រភេទនៃរូបិយប័ណ្ណ សមមូលនឹងដុល្លារអាមេរិក | | | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | ផ្សេងៗ | សរុប |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 486,615 | 5,648,315 | - | 6,134,930 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 2,883,740 | 113,855,516 | - | 116,739,256 |
| សមតុល្យនៅធនាគារនានា | 205,830 | 9,093,511 | 72,129 | 9,371,470 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់ គ្រឹះស្ថានហិរញ្ញវត្ថុនានា | 41,614,515 | 34,801,253 | - | 76,415,768 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | 18,259,949 | 345,961,941 | - | 364,221,890 |
| មូលបត្រវិនិយោគ | 976,336 | 5,045,216 | - | 6,021,552 |
| ទ្រព្យសកម្មផ្សេងៗ | - | 256,227 | - | 256,227 |
| | 64,426,985 | 514,661,979 | 72,129 | 579,161,093 |

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(ii). ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (ត)*

**ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ (ត)**

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណ មានដូចខាងក្រោមៈ (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ប្រភេទនៃរូបិយប័ណ្ណ សមមូលនឹងដុល្លារអាមេរិក | | | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | ផ្សេងៗ | សរុប |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា | 693,153 | 84,304,404 | - | 84,997,557 |
| ប្រាក់បញ្ញើពីអតិថិជន | 458,405 | 80,617,784 | 61,000 | 81,137,189 |
| ប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល | - | 262,085,649 | - | 262,085,649 |
| ប្រាក់កម្ចី | 32,538,043 | - | - | 32,538,043 |
| បំណុលភតិសន្យា | - | 2,209,818 | - | 2,209,818 |
| បំណុលផ្សេងៗ | 2,816 | 704,304 | - | 707,120 |
| | 33,692,417 | 429,921,959 | 61,000 | 463,675,376 |
| ស្ថានភាពទ្រព្យសកម្មសុទ្ធ | 30,734,568 | 84,740,020 | 11,129 | 115,485,717 |
| ពាន់រៀល (កំណត់សម្គាល់ 5) | 126,534,217 | 348,874,662 | 45,818 | 475,454,697 |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(ii). ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (ត)*

**ការប្រមូលផ្តុំហានិភ័យរូបិយប័ណ្ណ (ត)**

ចំនួនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ តាមប្រភេទនៃរូបិយប័ណ្ណ មានដូចខាងក្រោម៖ (ត)

| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | ប្រភេទនៃរូបិយប័ណ្ណ សមមូលនឹងដុល្លារអាមេរិក | | | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | ផ្សេងៗ | សរុប |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | 392,199 | 5,898,606 | - | 6,290,805 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 5,456,742 | 112,597,754 | - | 118,054,496 |
| សមតុល្យនៅធនាគារនានា | 157,440 | 8,277,334 | 69,354 | 8,504,128 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា | 28,714,373 | 51,136,170 | - | 79,850,543 |
| ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន | 13,816,989 | 317,454,297 | - | 331,271,286 |
| ទ្រព្យសកម្មផ្សេងៗ | - | 273,410 | - | 273,410 |
| | 48,537,743 | 495,637,571 | 69,354 | 544,244,668 |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា | 623,824 | 96,798,996 | - | 97,422,820 |
| ប្រាក់បញ្ញើពីអតិថិជន | 194,196 | 82,875,074 | 64,967 | 83,134,237 |
| ប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល | - | 200,857,856 | - | 200,857,856 |
| ប្រាក់កម្ចី | 35,953,069 | - | - | 35,953,069 |
| បំណុលភតិសន្យា | - | 2,493,074 | - | 2,493,074 |
| បំណុលផ្សេងៗ | 240,899 | 738,461 | - | 979,360 |
| | 37,011,988 | 383,763,461 | 64,967 | 420,840,416 |
| ស្ថានភាពទ្រព្យសកម្មសុទ្ធ | 11,525,755 | 111,874,110 | 4,387 | 123,404,252 |
| ពាន់រៀល (កំណត់សម្គាល់ 5) | 46,955,926 | 455,775,124 | 17,873 | 502,748,923 |

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ឃ. ហានិភ័យទីផ្សារ (ត)

*(ii). ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស (ត)*

**ការវិភាគរំញោច**

សន្មតថា អថេរហានិភ័យផ្សេងទៀតនៅថេរជានិច្ច ភាពរំញោចនៃការប្តូររូបិយប័ណ្ណបរទេសសម្រាប់សាខាធនាគារនាកាលបរិច្ឆេទរាយការណ៍ត្រូវបានសង្ខេបដូចខាងក្រោម (បង្ហាញតែរូបិយប័ណ្ណដែលមានចំនួនច្រើនជាង 5% នៃស្ថានភាពចំហរសុទ្ធ និងត្រូវបានបង្ហាញជារូបិយប័ណ្ណជាក់លាក់របស់វានៅក្នុងតារាងខាងក្រោម។ សម្រាប់រូបិយប័ណ្ណផ្សេងទៀត ការបង្ហាញទាំងនេះត្រូវបានដាក់ជាក្រុម 'ផ្សេងៗ')៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | - 1% ការថយចុះ ដុល្លារអាមេរិក | + 1% ការកើនឡើង ដុល្លារអាមេរិក | - 1% ការថយចុះ ដុល្លារអាមេរិក | + 1% ការកើនឡើង ដុល្លារអាមេរិក |
| ប្រាក់រៀល | (307,346) | 307,346 | (115,258) | 115,258 |
| ផ្សេងៗ | (111) | 1,154,857 | (44) | 1,234,043 |
| | (307,457) | 1,462,203 | (115,302) | 1,349,301 |
| ពាន់រៀល (កំណត់សម្គាល់ 5) | (1,265,800) | 6,019,890 | (469,740) | 5,497,052 |

### ង. ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុង បុគ្គលិក ប្រព័ន្ធ ឬពីកត្តាខាងក្រៅ។ ហានិភ័យនេះ ត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឲ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្ម តាមរយៈអង្គភាពគ្រប់គ្រង និងគាំទ្រ ដែលឯករាជ្យពីអង្គភាពអាជីវកម្ម និងគណៈគ្រប់គ្រង។ ទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់ អនុលោមភាព ហានិភ័យលើគណនេយ្យ និងការក្លែងបន្លំ។

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ង. ហានិភ័យប្រតិបត្តិការ (ត)

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់សាខាធនាគារ តម្រូវឲ្យបង្កើតនូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្រ្តនៃការគ្រប់គ្រងរបស់អង្គភាពឲ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្ត រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារយោងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនិងហានិភ័យប្រតិបត្តិការ ដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់សាខាធនាគារ។

### ច. ការគ្រប់គ្រងដើមទុន

#### *(i). ដើមទុនតាមបទប្បញ្ញត្តិ*

គោលដៅរបស់សាខាធនាគារក្នុងការគ្រប់គ្រងដើមទុន មានន័យទូលំទូលាយជាង "មូលធន" ដែលបង្ហាញក្នុង របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់សាខាធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម ដូចនេះ សាខាធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងសាខាធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលនយោបាយរបស់សាខាធនាគារ គឺធានាឲ្យបាននូវមូលដ្ឋានដើមទុនរឹងមាំដើម្បីរក្សានូវទំនុកចិត្តទីផ្សារ និងដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍឍយូរអង្វែងរបស់អាជីវកម្ម។ ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើ ភាគលាភរបស់សាខាធនាគារ ក៏ត្រូវបានទទួលស្គាល់ ហើយសាខាធនាគារបានទទួលស្គាល់នូវតម្រូវការ ដើម្បីធានាបាននូវ តុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនិងប្រាក់បម្រុងកម្រិតខ្ពស់ អត្ថប្រយោជន៍ និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

## 35. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ច. ការគ្រប់គ្រងដើមទុន (ត)

#### *(i). ដើមទុនតាមបទប្បញ្ញត្តិ (ត)*

តារាងខាងក្រោមសង្ខេបសមាសភាពនៃដើមទុនបទប្បញ្ញត្តិៈ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ដើមទុនថ្នាក់ទី 1** | | | | |
| ដើមទុន | 90,000,000 | 360,000,000 | 90,000,000 | 360,000,000 |
| ប្រាក់ចំណេញរក្សាទុក | 8,183,171 | 33,856,799 | 15,312,928 | 63,248,143 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទហិរញ្ញវត្ថុចុងក្រោយដែលបានធ្វើសវនកម្មរួច | 12,136,246 | 49,600,837 | 13,839,486 | 56,299,029 |
| ដកៈ ទ្រព្យសកម្មអរូបី | (198,372) | (816,698) | (314,792) | (1,282,463) |
| | 110,121,045 | 442,640,938 | 118,837,622 | 478,264,709 |
| **ដើមទុនថ្នាក់ទី 2** | | | | |
| សំវិធានធនទូទៅ | 4,203,917 | 17,307,526 | 3,881,794 | 15,814,429 |
| ដកៈ ការចូលភាគហ៊ុនក្នុងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ | - | - | - | - |
| | 4,203,917 | 17,307,526 | 3,881,794 | 15,814,429 |
| | 114,324,962 | 459,948,464 | 122,719,416 | 494,079,138 |

#### *(ii). ការបែងចែកដើមទុន*

ការបែងចែកដើមទុនរវាងប្រតិបត្តិការ និងសកម្មភាពជាក់លាក់ គឺត្រូវបានគ្រប់គ្រងដោយកម្រិតធំមួយ ត្រូវបានជំរុញការបង្កើនដោយប្រសិទ្ធភាព ដែលទទួលបានពីការបែងចែកនោះ។ ចំនួននៃដើមទុនដែលបានបែងចែកទៅតាមប្រតិបត្តិការ ឬសកម្មភាពនីមួយៗ គឺត្រូវបានផ្អែកទៅលើដើមទុនតាមបទប្បញ្ញត្តិ។

## 36. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ តម្លៃសមស្រប គឺជាថ្លៃដែលទទួលបានក្នុងការលក់ទ្រព្យសកម្ម ឬបានទូទាត់ ដើម្បីផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារ ឬប្រសិនអវត្តមាន ទីផ្សារដែលមានការរីកចម្រើនបំផុតដែលសាខាធនាគារអាចរកបាននៅកាលបរិច្ឆេទនោះ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឲ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទរាយការណ៍នៃស្ថានភាពហិរញ្ញវត្ថុ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន ហើយអាចរកបាន ត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចអង្កេតបាន មិនអាចរកបាននោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានអត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរទឹកប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ មិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 7៖ *ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុ* ដែលតម្រូវឲ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់សាខាធនាគារ មានដូចជាសាច់ប្រាក់ និងសាច់ប្រាក់សមមូលឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ទ្រព្យសកម្មផ្សេងៗ ប្រាក់កម្ចី និងបំណុលផ្សេងៗ មិនមានលក្ខណៈជាសារវន្តចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ ដូច្នេះ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទនៃស្ថានភាពហិរញ្ញវត្ថុមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

ការវាស់វែងតម្លៃសមស្រប គឺត្រូវបានផ្អែកលើវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

### ក. សមតុល្យនៅធនាគារជាតិនៃកម្ពុជា និងសមតុល្យនៅធនាគារនានា

តម្លៃសមស្របនៃសមតុល្យនៅធនាគារជាតិនៃកម្ពុជា និងសមតុល្យនៅធនាគារនានា ដែលមានអាយុកាលតិចជាងមួយឆ្នាំ គឺប្រហាក់ប្រហែលនឹងតម្លៃយោង។

## 36. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

### ខ. ឥណទាន និងបុរេប្រទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា និង ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនវាស់វែងតាមរំលស់ថ្លៃដើម

សម្រាប់ឥណទានដែលមានអត្រាថេរដោយមានរយៈពេលដែលនៅសល់រហូតដល់កាលវសាន្តតិចជាង ឬលើសពីមួយឆ្នាំនោះ ជាទូទៅតម្លៃយោងត្រូវបានប៉ាន់ស្មានថាមានតម្លៃប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របរបស់ពួកវា។

### គ. មូលបត្រវិនិយោគវាស់វែងតាមរំលស់ថ្លៃដើម

សម្រាប់មូលបត្រវិនិយោគក្នុងអត្រាថេរដែលមានរយៈពេលដែលនៅសល់រហូតដល់កាលកំណត់តិចជាង ឬលើសពីមួយឆ្នាំនោះ ជាទូទៅគឺការប៉ាន់ស្មានសមហេតុផលនៃតម្លៃសមស្របរបស់ពួកគេ។

### ឃ. ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល

តម្លៃសមស្របនៃប្រាក់បញ្ញើដែលត្រូវទូទាត់តាមតម្រូវការ (គណនីចរន្ត និងគណនីសន្សំ) ឬប្រាក់បញ្ញើដែល មានកាលកំណត់សងនៅសល់រយៈពេលតិចជាងមួយឆ្នាំ ត្រូវបានប៉ាន់ស្មានថាមានតម្លៃប្រហាក់ប្រហែល នឹងតម្លៃយោងរបស់វា។ តម្លៃសមស្របនៃប្រាក់បញ្ញើដែលមានកាលកំណត់សងនៅសល់រយៈពេលលើសពីមួយឆ្នាំ ត្រូវបានប៉ាន់ស្មានដោយផ្អែកតាមលំហូរទឹកប្រាក់អប្បហារ ដោយប្រើអត្រាទីផ្សារចំពោះប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ប្រាក់បញ្ញើរបស់អតិថិជនស្រដៀងគ្នា។

### ង. ប្រាក់កម្ចី

ប្រាក់កម្ចី មិនត្រូវបានដកស្រង់ពីទីផ្សារសកម្មទេ ហើយតម្លៃសមស្របរបស់វាគឺប្រហាក់ប្រហែលទៅនឹងតម្លៃយោង។

### ច. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងៗ

តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះមិនមានតម្លៃប្រែប្រួលជាសារវន្តទៅតាមអត្រាការប្រាក់ទីផ្សារទេ។

## 36. តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ (ត)

### ឆ. ឋានានុក្រមតម្លៃសមស្រប

ស.រ.ហ.អ.ក 7 បញ្ជាក់ពីឋានានុក្រមនៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេស វាយតម្លៃទាំងនោះអាចអង្កេតបាន ឬមិនអាចអង្កេតបាន។ យោងតាម ស.រ.ហ.អ.ក 13 ទិន្នន័យដែលអាចអង្កេតបានឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចអង្កេតបានឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់សាខាធនាគារ។ ឋានានុក្រមតម្លៃសមស្របមានដូចខាងក្រោម៖

- កម្រិតទី1 - តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុល ស្រដៀងគ្នា។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងឧបករណ៍បំណុល។
- កម្រិតទី2 - ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី1 ដែលអាចធ្វើការអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬដោយប្រយោល (ឧទាហរណ៍កើតចេញពីតម្លៃ) ។
- កម្រិតទី3 - ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ទិន្នន័យមិនអាចអង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុល ដែលមានសមាសធាតុមិនអាចអង្កេតបានជាសារវន្ត។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់សាខាធនាគារ មិនត្រូវបានវាស់វែងតាមតម្លៃសមស្របទេ។ ដោយសារតម្លៃទីផ្សារដែលអាចផ្ទៀងផ្ទាត់បានគឺមិនអាចវាយតម្លៃបាន តម្លៃទីផ្សារមិនមានសម្រាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុមួយចំណែកធំរបស់សាខាធនាគារ ដូច្នេះហើយ តម្លៃសមស្របត្រូវបានសន្មតដោយអ្នកគ្រប់គ្រងយោងទៅតាមទម្រង់នៃទ្រព្យសកម្ម និងបំណុលទាំងនោះ។ តាមមតិរបស់អ្នកគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺជាតម្លៃប៉ាន់ស្មានដ៏សមហេតុផលសម្រាប់តម្លៃសមស្រប។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ

សាខាធនាគារ បានអនុវត្តគោលនយោបាយគណនេយ្យដែលមានដូចខាងក្រោមប្រកបដោយសង្គតិភាព នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ក. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងលើមូលដ្ឋានថ្លៃដើមដំបូង លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ខ. ប្រតិបត្តិការរូបិយប័ណ្ណបរទេស

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅតាមរូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ ដែលជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍។ ការចំណេញ ឬការខាតបង់ពីការប្តូររូបិយប័ណ្ណបរទេស គឺជាភាពខុសគ្នារវាងរំលស់ថ្លៃដើមជារូបិយប័ណ្ណមុខងារនៅដើមឆ្នាំ ដែលត្រូវបានធ្វើនិយ័តកម្មសម្រាប់ការប្រាក់ប្រសិទ្ធភាព និងការទូទាត់ក្នុងឆ្នាំធៀបនិងរំលស់ថ្លៃដើម ជារូបិយប័ណ្ណបរទេសដែលបានប្តូរដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទរាយការណ៍។

ទ្រព្យសកម្មមិនមែនជារូបិយវត្ថុ និងបំណុលដែលមិនមែនជារូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របជារូបិយប័ណ្ណ បរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងារនៅអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃត្រូវបានកំណត់។ ធាតុមិនមែនជារូបិយវត្ថុ ដែលត្រូវបានវាស់វែងផ្អែកលើតម្លៃប្រវត្តិសាស្រ្តជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ។

ភាពលម្អៀងរូបិយបណ្ណ័ដែលកើតពីការប្តូរ ជាទូទៅត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

### *(i). ការទទួលស្គាល់ និងការវាស់វែងដំបូង*

សាខាធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើ និងប្រាក់កម្ចី នៅកាលបរិច្ឆេទដែលប្រតិបត្តិការកើតមានឡើង។ រាល់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទាំងអស់ ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរ ដែលជាកាលបរិច្ឆេទដែលសាខាធនាគារក្លាយជាភាគីនៃបទប្បញ្ញត្តិកិច្ចសន្យានៃឧបករណ៍។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប សម្រាប់ឧបករណ៍ដែល មិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត បូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ។

### *(ii). ការចាត់ចំណាត់ថ្នាក់*

### ទ្រព្យសកម្មហិរញ្ញវត្ថុ

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងរំលស់ថ្លៃដើម FVOCI ឬ FVTPL។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបានបំពេញ និងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុក ដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii). ការចាត់ចំណាត់ថ្នាក់ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI ប្រសិនបើវាបានបំពេញ និងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុក ដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់។

សម្រាប់ការទទួលស្គាល់លើការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរសាខាធនាគារ ត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកតាមការវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀត ត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL។

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង សាខាធនាគារអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL និងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

**ការវាយតម្លៃគំរូអាជីវកម្ម**

សាខាធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅអ្នកគ្រប់គ្រង។ ព័ត៌មានដែលត្រូវបានពិចារណារួមមាន៖

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii). ការចាត់ចំណាត់ថ្នាក់ (ត)*

**ការវាយតម្លៃគំរូអាជីវកម្ម (ត)**

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនិងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឲ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម។
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់សាខាធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅ អំពីរបៀបដែលធ្វើឲ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់សាខាធនាគារ។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii). ការចាត់ចំណាត់ថ្នាក់ (ត)*

**ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យា គឺសម្រាប់ការទូទាត់តែប្រាក់ដើម និងការប្រាក់ប៉ុណ្ណោះ**

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" ត្រូវបានកំណត់ជាតម្លៃសមស្រប នៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ សាខាធនាគារត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឲ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។ ក្នុងការវាយតម្លៃ សាខាធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតសាខាធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃពេលវេលា (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

**ការចាត់ចំណាត់ថ្នាក់ឡើងវិញ**

ទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងរយៈពេលដែលសាខាធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iii). ការឈប់ទទួលស្គាល់*

### ទ្រព្យសកម្មហិរញ្ញវត្ថុ

សាខាធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានផ្ទេរ ឬក្នុងករណីដែលសាខាធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលបានទទួល (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

### បំណុលហិរញ្ញវត្ថុ

សាខាធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ។

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

### ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះសាខាធនាគារវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាជាសារវន្ត ឬទេ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ប្រសិនបើ លំហូរទឹកប្រាក់មានភាពខុសគ្នាជាសារវន្ត នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ។ ក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល(iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប បូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានទទួលស្គាល់ដូចខាងក្រោមៈ

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមកវិញពីថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀត ត្រូវបានរាប់បញ្ចូលក្នុងចំណេញ និងខាត ដែលជាផ្នែកមួយនៃចំណេញ ឬខាតលើទ្រព្យសកម្មដែលឈប់ទទួលស្គាល់។

ប្រសិនបើលំហូរទឹកប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌ នៃកិច្ចសន្យាដើមជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើសាខាធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ(សូមមើលខាងក្រោមសម្រាប់គោលនយោបាយការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះ ជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យជាទូទៅមិនអាចអនុវត្តបាននោះទេ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ សាខាធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។

ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានិងការខាតបង់លើឱនភាពនៃតម្លៃនៃទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព (សូមមើលកំណត់សម្គាល់ 38(ន))។

**បំណុលហិរញ្ញវត្ថុ**

សាខាធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ និងតម្លៃតបស្នងបានបង់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលរួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

**បំណុលហិរញ្ញវត្ថុ (ត)**

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនធ្វើឲ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធិភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែតម្រូវដោយគណនា អត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

**កំណែទម្រង់គោលការណ៍អត្រាការប្រាក់**

ប្រសិនបើមូលដ្ឋាននៃការកំណត់លំហូរទឹកប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើមមានការប្រែប្រួលដែលជាលទ្ធផលនៃកំណែទម្រង់អត្រាការប្រាក់ នោះសាខាធនាគារនឹងធ្វើបច្ចុប្បន្នភាព លើអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ។ ការផ្លាស់ប្តូរមូលដ្ឋានសម្រាប់កំណត់លំហូរទឹកប្រាក់តាមកិច្ចសន្យា គឺត្រូវបានតម្រូវដោយកំណែទម្រង់អត្រាការប្រាក់ ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ការផ្លាស់ប្តូរនេះចាំបាច់ជាលទ្ធផលផ្ទាល់នៃកំណែទម្រង់នេះ និង
- មូលដ្ឋានថ្មីសម្រាប់កំណត់លំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសមមូលនឹងមូលដ្ឋានពីមុន – ពោលគឺមូលដ្ឋាន ភ្លាមៗមុនពេលមានការផ្លាស់ប្តូរ។

ប្រសិនបើការផ្លាស់ប្តូរត្រូវបានធ្វើឡើងចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុបន្ថែមពីលើការផ្លាស់ប្តូរមូលដ្ឋានសម្រាប់កំណត់លំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលតម្រូវដោយកំណែទម្រង់អត្រាការប្រាក់ នោះសាខាធនាគារនឹងធ្វើបច្ចុប្បន្នភាពអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមុនសិន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលទាមទារដោយកំណែទម្រង់អត្រាការប្រាក់។ បន្ទាប់ពីនោះ សាខាធនាគារនឹងអនុវត្តគោលនយោបាយគណនេយ្យសម្រាប់ការកែប្រែដែលបានកំណត់ខាងលើ ចំពោះចំណាយបន្ថែម។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

#### *(v). ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កងគ្នា និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសាខាធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ចំណូល និងចំណាយ ត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធបាន លុះត្រាតែមានការអនុញ្ញាតពី ស.រ.ទ.ហ.អ.ក ឬអាចធ្វើទៅបានចំពោះចំណេញ ឬខាត ដែលកើតចេញពីក្រុមប្រតិបត្តិការដែលមានលក្ខណៈស្រដៀងគ្នា។

#### *(vi). ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារ គោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលសាខាធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

សាខាធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើប្រាស់សម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬ បំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណាក្នុងការកំណត់តម្លៃប្រតិបត្តិការមួយ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះសាខាធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃប្រតិបត្តិការមួយ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vi). ការវាស់វែងតម្លៃសមស្រប (ត)*

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល។ ប្រសិនបើសាខាធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

សាខាធនាគារ ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

*(vii). ឱនភាពនៃតម្លៃ*

សាខាធនាគារ ទទួលស្គាល់សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាឧបករណ៍បំណុល
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

សាខាធនាគារវាស់វែងការខាតបង់សំវិធានធន តាមចំនួនដែលស្មើនឹងការខាតបង់ឥណទានរំពឹងទុកពេញ អាយុកាល លើកលែងគណនីខាងក្រោម ដែលត្រូវវាស់វែងតាមការខាតបង់ឥណទានរំពឹងទុករយៈពេល 12ខែ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ការខាតបង់ឥណទានរំពឹងទុក12ខែ គឺជាផ្នែកនៃការខាតបង់ឥណទានរំពឹងទុក ដែលបណ្តាលមកពីព្រឹត្តិការណ៍ ខកខានសងប្រាក់ក្នុងរយៈពេល 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុក 12ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី1"។ ឧបករណ៍ហិរញ្ញវត្ថុដែលបានបែងចែកទៅក្នុងដំណាក់កាលទី 1 ពុំទាន់មានការកើនឡើងណាមួយជាសារវន្តនៅក្នុងហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង និងពុំទាន់មានឱនភាពនៃតម្លៃឥណទាននៅឡើយទេ។

ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ("Life-time ECL") គឺជាការខាតបង់ឥណទានរំពឹងទុកដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី2"។ ឧបករណ៍ហិរញ្ញវត្ថុដែលបានបែងចែកទៅក្នុងដំណាក់កាលទី 2 គឺជាឧបករណ៍ដែលមានបទពិសោធន៍លើការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់ដំបូង ប៉ុន្តែពុំទាន់មានឱនភាពនៃតម្លៃឥណទាននៅឡើយទេ។

ឧបករណ៍ហិរញ្ញវត្ថុដែលការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ត្រូវបានទទួលស្គាល់ ហើយឱនភាពនៃតម្លៃឥណទាន ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុដំណាក់កាលទី 3"។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

នៅកាលបរិច្ឆេទនៃរបាយការណ៍ សាខាធនាគារវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។ នៅពេលដែលហានិភ័យឥណទានកើនឡើជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែង តាមតម្លៃស្មើនឹងអាយុកាលនៃការខាតបង់ឥណទានរំពឹងទុក។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានការខាតបង់ឥណទានរំពឹងទុក នោះសាខាធនាគារពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធនិងអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្ពស់។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់សាខាធនាគារ និងការវាយតម្លៃឥណទាន ព្រមទាំងបញ្ចូលព័ត៌មានប្រមើលមើលអនាគត។

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើ គុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឲ្យគ្មានការកើនឡើងជាសារវន្តនូវហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការខាតបង់ឥណទានរំពឹងទុក 12ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការខាតបង់ឥណទានរំពឹងទុក គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលសាខាធនាគារប្រឈមនឹងហានិភ័យឥណទាន។

**ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន**

សាខាធនាគារវាយតម្លៃថាតើមានហានិភ័យឥណទានបានកើនឡើងជាសារវន្ត ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូង នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត អាស្រ័យលើលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអ្នកខ្ចី និងតំបន់ភូមិសាស្ត្រ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន (ត)**

សាខាធនាគារ ពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត កើតឡើងនៅពេលទ្រព្យសកម្ម មានការខកខានសងមិនតិចជាងរយៈពេលចំនួន 30ថ្ងៃ។ ចំនួនថ្ងៃខកខានសង ត្រូវបានកំណត់ដោយការ រាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលការបង់សងទាំងអស់មិនទាន់បានទទួល។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែល អាចមានសម្រាប់ អ្នកខ្ចីឡើយ។

ប្រសិនបើ មានភស្តុតាងដែលបញ្ជាក់ថាមិនមានការកើនឡើងពីហានិភ័យឥណទានជាសារវន្តទាក់ទងនឹង ការ ទទួលស្គាល់លើកដំបូងទេ នោះសំវិធានធននៃការខាតបង់លើឧបករណ៍ហិរញ្ញវត្ថុមួយនឹងត្រឡប់ទៅ ត្រូវបានវាស់វែងតាម ECL 12ខែ។

**ការបង្កើតក្រុមនៃទ្រព្យសកម្មដែលហានិភ័យឥណទានមានលក្ខណៈស្រដៀងគ្នា**

នៅពេលដែល ECLs ត្រូវបានវាស់វែងតាមមូលដ្ឋានជាក្រុម ឧបករណ៍ហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំតាមមូលដ្ឋាន ចរិតលក្ខណៈហានិភ័យ។ សាខាធនាគារធ្វើការតាមដានភាពសមស្របនៃលក្ខណៈហានិភ័យឥណទានដោយ ផ្អែកលើមូលដ្ឋានត្រួតពិនិត្យជាប្រចាំ ដើម្បីវាយតម្លៃថាតើហានិភ័យទាំងនោះនៅតែបន្តលក្ខណៈស្រដៀង គ្នាដែរ ឬទេ។ កិច្ចការនេះ ត្រូវធ្វើដើម្បីធានាថា ប្រសិនបើចរិតលក្ខណៈហានិភ័យឥណទានមានការផ្លាស់ប្តូរ គឺ ត្រូវធ្វើការប្រមូលផ្តុំទ្រព្យសកម្មឲ្យបានសមស្របឡើងវិញ។ ការប្រមូលផ្តុំឡើងវិញនេះអាចនាំឲ្យមាននូវការ បង្កើតក្រុមទ្រព្យសកម្មថ្មី ឬក៏ទ្រព្យសកម្មត្រូវប្តូរទៅក្រុមទ្រព្យសកម្មដែលមានស្រាប់ផ្សេងទៀត ដែល អាចឆ្លុះបញ្ចាំងនូវចរិតលក្ខណៈហានិភ័យឥណទានស្រដៀងគ្នាទៅនឹងក្រុមទ្រព្យសកម្មនោះ។ ការប្រមូលផ្តុំ ទ្រព្យសកម្មឡើងវិញ និងការប្តូរពីក្រុមទ្រព្យសកម្មមួយទៅក្រុមទ្រព្យសកម្មមួយទៀត គឺជារឿងធម្មតា នៅ ពេលមានការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន (ឬក៏នៅពេលការកើនឡើងជាសារវន្តនោះ មានភាព បញ្ច្រាសមកវិញ) ដូច្នេះ ទ្រព្យសកម្ម ត្រូវប្តូរពីទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធននៃការខាតបង់ឥណទានដែល រំពឹងទុកស្មើនឹង 12 ខែ ទៅជាទ្រព្យសកម្មដែលត្រូវធ្វើសំវិធានធនស្មើនឹងអាយុកាលរបស់ ទ្រព្យសកម្មនោះ ឬ ក៏បញ្ច្រាសមកវិញ ប៉ុន្តែ វាក៏អាចកើតឡើងផងដែរចំពោះក្រុមទ្រព្យសកម្ម ដែលនៅតែបន្តវាស់វែងតាមមូល ដ្ឋាន 12ខែ ឬសំវិធានធនស្មើនឹងអាយុកាលរបស់ក្រុមទ្រព្យសកម្មនោះ គ្រាន់តែចំនួនសំវិធានធនត្រូវផ្លាស់ប្តូរ ដោយសារហានិភ័យឥណទានរបស់ក្រុមទ្រព្យសកម្មនោះមានការប្រែប្រួល។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**និយមន័យនៃការខកខានសង**

សាខាធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- សាខាធនាគារ កំណត់ថាការកើនឡើងនៃហានិភ័យឥណទានកើតឡើងនៅពេលទ្រព្យសកម្មហួសកាលកំណត់ច្រើនជាងឬស្មើ 30ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី និង90ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬ
- វាមានភាពច្បាស់លាស់ដែលថា អ្នកខ្ចីនឹងរៀបចំទ្រព្យសកម្មឡើងវិញក្រោយពីក្ស័យធនដោយសារអ្នកខ្ចី ពុំមានលទ្ធភាពសងកាតព្វកិច្ចឥណទានបាន។

**ការវាស់វែងការខាតបង់ឥណទានរំពឹងទុក**

ការខាតបង់ឥណទានរំពឹងទុក គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន។ ការខាតបង់ឥណទានរំពឹងទុក ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់សាខាធនាគារស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលសាខាធនាគាររំពឹងទុកថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលជំពាក់សាខាធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលសាខាធនាគារ រំពឹងទុកថានឹងទទួលបាន ប្រសិនបើឥណទានត្រូវបានដកប្រើ និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការរំពឹងទុកនៃការបង់ប្រាក់ដើម្បីសងវិញ ដកចំនួនទឹកប្រាក់ដែលសាខាធនាគាររំពឹងថានឹងទទួលបានមកវិញ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ការវាស់វែងការខាតបង់ឥណទានរំពឹងទុក (ត)**

នៅពេលធ្វើអប្បហារលំហូរទឹកប្រាក់នាពេលអនាគត អត្រាអប្បហារខាងក្រោមត្រូវបានប្រើប្រាស់៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញ ឬនៅពេលដំបូង និងភតិសន្យាត្រូវទទួលះ អត្រាការប្រាក់ប្រសិទ្ធភាពដើម ឬប្រហាក់ប្រហែល
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញ ឬនៅពេលដំបូង និងភតិសន្យាត្រូវទទួលះ អត្រាការប្រាក់ប្រសិទ្ធភាពកែតម្រូវឥណទាន
- កិច្ចសន្យាឥណទានដែលនៅសល់៖ អត្រាការប្រាក់ប្រសិទ្ធភាព ឬប្រហាក់ប្រហែលនឹងត្រូវអនុវត្ត ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលជាលទ្ធផលមកពីកិច្ចសន្យាឥណទាន និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុបានបោះផ្សាយ៖ អត្រាដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃ ពេលវេលា និងហានិភ័យដែលជាក់លាក់ចំពោះលំហូរទឹកប្រាក់។

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ**

សមាសធាតុសំខាន់ៗក្នុងការវាស់វែងលើការខាតបង់ឥណទានរំពឹងទុក គឺបានមកពីអថេរដូចខាងក្រោម៖

- លទ្ធភាពនៃការខកខានសង ("PD")
- ការបាត់បង់ដែលបណ្ដាលមកពីការខកខានសង ("LGD") និង
- ទំហំនៃការខកខានសង ("EAD")។

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី1 ត្រូវបានគណនាដោយផលគុណនៃ PD 12ខែ និង LGD និង EAD។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល និង LGD និង EAD។

គំរូស្ថិតិ ត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន PD ពេញអាយុកាល ដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)**

សាខាធនាគារទទួលយកម៉ាទ្រីសការផ្លាស់ប្តូរដោយផ្អែកលើការខកខាន គំរូអត្រាការខាតបង់ដើមដំបូង និង គំរូប្រូកស៊ី ដើម្បីប៉ាន់ស្មាន PD របស់វា។

សាខាធនាគារប្រើប្រាស់ម៉ូឌែល Proxy ដើម្បីប៉ាន់ប្រមាណ PD របស់ខ្លួន។ ម៉ូឌែល Proxy ពីការិយាល័យកណ្តាលមានប៉ារ៉ាម៉ែត្រជាច្រើន ដូចជា PD ជាមួយចំណាត់ថ្នាក់ពីខាងក្រៅ PDជាមួយចំណាត់ថ្នាក់ពីខាងក្នុង និងPD ដែលគ្មានចំណាត់ថ្នាក់ពីខាងក្នុង និងខាងក្រៅ ដែលក្នុងនោះ ម៉ូឌែល PD ទាំងនេះ បានបញ្ចូលព័ត៌មានប្រមើលមើលអនាគត ដែលត្រូវបានកែតម្រូវនៅកម្រិតការិយាល័យកណ្តាល។

LGD គឺជាទំហំនៃភាពអាចបាត់បង់ ប្រសិនបើមានការខកខានសង។ សាខាធនាគារប្រើប្រាស់ LGD ដោយផ្អែកលើម៉ូឌែល Proxy ពីការិយាល័យកណ្តាល។ សាខាធនាគារប៉ាន់ស្មាន LGD ដែលបានបញ្ចូលព័ត៌មានប្រមើលមើលអនាគតប៉ារ៉ាម៉ែត្រ ដោយផ្អែកលើប្រវត្តិនៃអត្រាប្រមូលបានមកវិញពីភាគីដែលខកខានសងប្រាក់។ ស្មាន LGD ដែលបានបញ្ចូលព័ត៌មានប្រមើលមើលអនាគត ពិចារណាលើរចនាសម្ព័ន្ធ វត្ថុបញ្ចាំ អតីតភាពនៃការទាមទារ ឧស្សាហកម្មសមភាគី និងការចំណាយលើការស្តារឡើងវិញនៃវត្ថុបញ្ចាំណាមួយដែលជាធាតុនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

EAD តំណាងឲ្យតម្លៃសមតុល្យដែលប៉ះពាល់ នៅពេលមានការខកខានសង។ សាខាធនាគារទាញយក EAD សម្រាប់ធាតុនៅលើតារាងតុល្យការពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់។

EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយ គឺជាតម្លៃយោងដុល និងការប្រាក់ត្រូវទទួលបង្គរនៅពេលមានការខកខានសង។ លើសពីនេះទៅទៀត សាខាធនាគារ ប្រើប្រាស់ EAD នៃធាតុក្រៅតារាងតុល្យការ ដោយផ្អែកតាម Credit Conversion factor ("CCF") ពីការិយាល័យកណ្តាល។

ដូចដែលបានរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី1 សាខាធនាគារវាស់វែងការខាតបង់ឥណទានការរំពឹងទុក ដោយពិចារណាលើហានិភ័យនៃការខកខានសងលើរយៈពេលនៃកិច្ចសន្យាជាអតិបរមា (រួមបញ្ចូលទាំងរយៈពេលពន្យារ ប្រសិនបើមាន) ដែលមានហានិភ័យឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទាន សាខាធនាគារពិចារណាលើរយៈពេលវែង។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលសាខាធនាគារមានសិទ្ធិដើម្បីទាមទារការសងត្រឡប់ នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)**

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិនបណ្តាលឲ្យឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់នោះទេ នោះលំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ បណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ននៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពី កាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ សាខាធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី3")។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពឥណទាននៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)**

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន (ត)*

ភស្តុតាងដែលទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពឥណទាន រួមមាននូវទិន្នន័យដែលសង្កេតបានដូចជា៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលសាខាធនាគារមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពអវិជ្ជមាននៅក្នុងលក្ខខណ្ឌរបស់អ្នកខ្ចី ត្រូវបានចាត់ទុកជាឥណទានមានឱនភាពឥណទាន លុះត្រាតែ មានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង 90ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង ឬ 30ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី ត្រូវបានចាត់ទុកជាឥណទានមានឱនភាពឥណទាន ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

**ការបង្ហាញនៃសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

សំវិធានធននៃការខាតបង់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដូចខាងក្រោម៖

- *ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃរំលស់៖* ជាការកាត់ចេញពីតម្លៃយោងដុលនៃទ្រព្យសកម្ម
- *កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានារ៉ាប់រងហិរញ្ញវត្ថុ៖* ជាទូទៅគឺជាសំវិធានធន

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

**ការបង្ហាញនៃសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)**

- *នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងសមាសភាគដែលបានប្រើប្រាស់ និងនៅសល់ ហើយសាខាធនាគារមិនអាចកំណត់ ECL លើសមាសភាគកិច្ចសន្យាឥណទានដាច់ដោយឡែកពីសមាសភាគ កិច្ចសន្យាឥណទានដែលបានប្រើប្រាស់៖* សាខាធនាគារត្រូវបង្ហាញសំវិធានធនរួមបញ្ចូលគ្នានៃការខាតបង់សម្រាប់ទាំងពីរសមាសភាគ។ ចំនួនទឹកប្រាក់រួមបញ្ចូលគ្នា ត្រូវបានបង្ហាញជាការកាត់ចេញពីចំនួនដុលនៃសមាសភាគដែលបានប្រើប្រាស់។ ចំនួនសំវិធានធនលើការខាតបង់ដែលលើសពីចំនួនដុលនៃសមាសភាគដែលបានប្រើប្រាស់ត្រូវបង្ហាញជាសំវិធានធន។

**ការលុបចោល**

ឥណទាន និងបុរេប្រទានត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលសាខាធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុចំណូលផ្សេងៗ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឲ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់សាខាធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឃ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យក្នុងធនាគារ ប្រាក់បញ្ញើតាមតម្រូវការ និងទ្រព្យសកម្មហិរញ្ញវត្ថុរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងរយៈពេល 3ខែ ឬតិចជាង ចាប់ពីកាលបរិច្ឆេទនៃការទិញ ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួច ចំពោះការផ្លាស់ប្តូរតម្លៃ ហើយត្រូវបានប្រើប្រាស់ដោយសាខាធនាគារក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

### ង. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដកឱនភាពនៃតម្លៃ ដែលមិនអាចប្រមូលមកវិញបាន។

### ច. ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើសរុបរបស់អតិថិជន។ ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ ត្រូវបានកត់ត្រាតាមថ្លៃដើម។

### ឆ. ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា" និង "ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទាន និងបុរេប្រទានដែលវាស់វែងតាមរំលស់ថ្លៃដើម។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព។

### ជ. មូលបត្រវិនិយោគ

'មូលបត្រវិនិយោគ' នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមមាន ការវិនិយោគលើមូលបត្របំណុល ដែល វាស់វែងតាមរំលស់ថ្លៃដើម (សូមមើលកំណត់សម្គាល់ 38គ(ii))។ ការវិនិយោគលើមូលបត្របំណុលទាំងនេះ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការដោយផ្ទាល់ និងនៅពេលបន្តបន្ទាប់ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឈ. ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន។

### ញ. ទ្រព្យ និងបរិក្ខារ

*(i). ការទទួលស្គាល់ និងការវាស់វែង*

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានវាស់វែងតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។

ចំណាយថ្លៃដើមរួមបញ្ចូលទាំងការចំណាយដោយផ្ទាល់ទៅលើការទិញទ្រព្យ និងការចំណាយដោយផ្ទាល់ផ្សេងៗទៀត ក្នុងការនាំយកទ្រព្យសកម្មទៅក្នុងលក្ខខណ្ឌដែលអាចប្រើប្រាស់ដែលបានគ្រោងទុក និងថ្លៃដើមនៃការរុះរើ និងផ្លាស់ប្តូរទីកន្លែង និងការស្តារទីតាំងដែលពួកគេស្ថិតនៅ។ ថ្លៃដើមនៃទ្រព្យកម្មដែលបានសាងសង់ដោយសាខាធនាគារផ្ទាល់ ត្រូវរួមបញ្ចូលទាំងថ្លៃដើមសម្ភារៈ និងកម្លាំងពលកម្មផ្ទាល់ផងដែរ។ ចំពោះទ្រព្យសកម្មដែលមានលក្ខណៈគ្រប់គ្រាន់ ការចំណាយលើប្រាក់កម្ចី ត្រូវបានធ្វើមូលធនកម្មស្របតាមគោលនយោបាយគណនេយ្យលើថ្លៃដើមប្រាក់កម្ចី។ ថ្លៃដើមក៏អាចរួមបញ្ចូលទាំងការផ្ទេរមូលធនដែលជាចំណេញ ឬខាតណាមួយផងដែរលើការការពារហានិភ័យលំហូរទឹកប្រាក់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំពោះរូបិយប័ណ្ណបរទេសទាក់ទងនឹងការទិញទ្រព្យ និងបរិក្ខារ។

ការទិញសូហ្វវែរដែលមានសារៈសំខាន់ចំពោះមុខងារដែលទាក់ទងនឹងបរិក្ខារ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃបរិក្ខារនោះ។

នៅពេលដែលផ្នែកជាសារវន្តណាមួយនៃទ្រព្យ និងបរិក្ខារទាំងនោះ មានអាយុកាលប្រើប្រាស់ខុសពីគ្នា ផ្នែកទាំងនោះត្រូវបានដាក់ជាផ្នែកដោយឡែក (សមាសភាពចម្បង) នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតពីការលក់នៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃទ្រព្យ និងបរិក្ខារ ហើយត្រូវបានទទួលស្គាល់សុទ្ធនៅក្នុង "ចំណូលផ្សេងៗ" និង "ចំណាយផ្សេងៗ" រៀងគ្នានៅក្នុងចំណេញ ឬខាត។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ញ. ទ្រព្យ និងបរិក្ខារ (ត)

*(ii). ចំណាយបន្ទាប់*

ថ្លៃដើមនៃការផ្លាស់ប្តូរជាតុមួយផ្នែកនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូល នៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់សាខាធនាគារ ហើយតម្លៃរបស់វាអាចធ្វើការវាស់វែងបានដោយភាពអាចជឿជាក់បាន។ តម្លៃយោង នៃធាតុដែលបានជំនួសនោះ ត្រូវឈប់ទទួលស្គាល់ក្នុងចំណេញ ឬខាត។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗនៃទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត នៅពេលកើតឡើង។

*(iii). រំលស់*

រំលស់ត្រូវបានគណនាដើម្បីលុបចោលនូវថ្លៃដើមរបស់ទ្រព្យ និងបរិក្ខារ ដកតម្លៃកាកសំណល់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារ និងត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាត។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារ សម្រាប់ការិយបរិច្ឆេទនេះ និងការិយបរិច្ឆេទមុនមានដូចខាងក្រោមៈ

| | |
|---|---|
| ការកែលម្អទ្រព្យជួល | 5ឆ្នាំ |
| ម៉ាស៊ីនការិយាល័យ | 5ឆ្នាំ |
| គ្រឿងសង្ហារឹម គ្រឿងបំពាក់ និងបរិក្ខារ | 4ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា | 4ឆ្នាំ |
| យានយន្ត | 5ឆ្នាំ |

វិធីសាស្ត្ររំលស់ លើអាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនាចុងការិយបរិច្ឆេទនៃរបាយការណ៍ និងនិយ័តភាពប្រសិនបើសមស្រប។

ទ្រព្យកំពុងបង្កើត មិនត្រូវបានរំលស់រហូតដល់ទ្រព្យនោះត្រូវបានបញ្ចប់ ហើយដាក់ឲ្យប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្ម។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ញ. ទ្រព្យ និងបរិក្ខារ (ត)

*(iii). រំលស់ (ត)*

នៅពេលដែលទ្រព្យសកម្មត្រូវបានលក់ ថ្លៃដើម និងរំលស់បង្គរ ត្រូវបានដកចេញពីគណនី។ ប្រាក់ចំណេញ ឬខាតជាលទ្ធផលពីការលក់ចេញ ត្រូវបានរួមបញ្ចូលនៅក្នុងចំណេញ ឬខាត។ ប្រាក់ចំណេញ និងខាតលើការលក់ចេញ ត្រូវបានកំណត់ដោយការប្រៀបធៀបសាច់ប្រាក់ចំណូលជាមួយតម្លៃយោង។ ទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងចំណេញ ឬខាត នៅក្នុងខ្ទង់"ចំណូលពីប្រតិបត្តិការផ្សេងៗ"។ នៅពេលដែលទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញត្រូវបានលក់ ចំនួនទឹកប្រាក់ដែលរួមបញ្ចូលនៅក្នុងអតិរេកនៃការវាយតម្លៃឡើងវិញ ត្រូវបានផ្ទេរទៅប្រាក់ចំណេញរក្សាទុក។

ទ្រព្យសកម្មដែលបានរំលស់ពេញលេញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យសកម្មទាំងនោះលែងប្រើប្រាស់ ហើយមិនមានរំលស់ ត្រូវបានធ្វើឡើងទាក់ទងនឹងទ្រព្យសកម្មទាំងនេះទេ។

### ដ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមអាជ្ញាប័ណ្ណកុំព្យូទ័រដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ អាជ្ញាប័ណ្ណកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។

1 សូហ្វវែរ ត្រូវបានធ្វើរំលស់នៅក្នុងចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋានរំលស់ថេរ ទៅតាមអាយុកាល ប្រើប្រាស់ប៉ាន់ស្មាន គិតចាប់ពីពេលដែលអាចប្រើប្រាស់បាន។ អាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃសូហ្វវែរ សម្រាប់ការិយបរិច្ឆេទនេះ និងការិយបរិច្ឆេទមុនគឺ 5ឆ្នាំ។

សូហ្វវែរដែលកំពុងអភិវឌ្ឍ រួមបញ្ចូលទាំងការចំណាយលើការបង្កើតកម្មវិធីសូហ្វវែរថ្មីដែលមិនទាន់បានបញ្ចប់ទាំងស្រុងនាកាលបរិច្ឆេទរាយការណ៍។ កម្មវិធីសូហ្វវែរដែលកំពុងអភិវឌ្ឍមិនត្រូវបានរំលស់រហូតដល់ពេល ដែលកម្មវិធីសូហ្វវែរពាក់ព័ន្ធត្រូវបានបញ្ចប់ និងដាក់ឲ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

ថ្លៃដើមពាក់ព័ន្ធនឹងការបង្កើត ឬថែទាំកុំព្យូទ័រសូហ្វវែរ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលកើតឡើង។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឋ. ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា សាខាធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរឬទេ។ កិច្ចសន្យាមានទម្រង់ជាភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់ ជាថ្នូរនឹងតម្លៃតបស្នង។

**ភតិសន្យាក្នុងករណីដែលសាខាធនាគារជាភតិក:**

នៅពេលចាប់ផ្តើមកិច្ចសន្យា ឬវាយតម្លៃឡើងវិញលើកិច្ចសន្យាដែលមានទម្រង់ជាភតិសន្យា និងសមាសធាតុ ដែលមិនមែនភតិសន្យា សាខាធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យានីមួយៗ និងសមាសធាតុដែលមិនមែនភតិសន្យា ដោយផ្អែកតាមតម្លៃឯកតានីមួយៗ។ ក៏ប៉ុន្តែចំពោះការជួលដីធ្លី និងអគារដែលសាខាធនាគារជាអ្នកជួល សាខាធនាគារជ្រើសរើសអនុវត្តមិនបែងចែកសមាសធាតុមិនមែនភតិសន្យានោះទេ ហើយសមាសធាតុភតិសន្យា និងមិនមែនភតិសន្យាត្រូវបានចាត់ទុកថាជាសមាសធាតុភតិសន្យាតែមួយ។

សាខាធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងតាមថ្លៃដើម រួមមានថ្លៃដើមដំបូងនៃបំណុលភតិសន្យា និងនិយ័តភាពសម្រាប់ការចំណាយភតិសន្យាដែលធ្វើឡើងនៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុន ថ្ងៃចាប់ផ្តើមភតិសន្យា បូកថ្លៃដើមផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មានចំណាយក្នុងការរុះរើ និងដកចេញនូវទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីតាំងដែលទ្រព្យសម្មស្ថិតនៅ ដកប្រាក់លើកទឹកចិត្តភតិសន្យាដែលទទួលបាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានដករំលស់នាពេលបន្តបន្ទាប់ តាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុងកាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើបំណុលភតិសន្យា។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

- អគារ និងការិយាល័យ 3 – 10ឆ្នាំ

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឋ. ភតិសន្យា (ត)

*ភតិសន្យាក្នុងករណីដែលសាខាធនាគារជាជាភតិក: (ត)*

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់ នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗ ត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់អ្នកជួល។ ជាទូទៅ សាខាធនាគារប្រើប្រាស់អត្រាការប្រាក់កម្ចីបន្ថែមរបស់ខ្លួនជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមានៈ

- ការទូទាត់ភតិសន្យាថេរ រួមទាំងការទូទាត់ក្នុងទម្រង់ថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យាអថេរ ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃទិញក្រោមជម្រើសនៃការទិញ ដែលសាខាធនាគារមានហេតុផលជាក់លាក់ក្នុងការអនុវត្ត។ ការទូទាត់ភតិសន្យានៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើសាខាធនាគារមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យលើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែសាខាធនាគារមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យា ត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរលើការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគតដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើមានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់ លើការធានាតម្លៃដែលនៅសល់ ប្រសិនបើសាខាធនាគារផ្លាស់ប្តូរការវាយតម្លៃរបស់ខ្លួន ថាតើសាខាធនាគារនឹងអនុវត្តសិទ្ធិក្នុងការទិញ ការពន្យារ ឬជម្រើសបញ្ចប់ ឬប្រសិនបើមានការកែសម្រួលការទូទាត់ភតិសន្យាថេរ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះ ការកែតម្រូវត្រូវបានធ្វើឡើងលើតម្លៃយោងនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយរហូតដល់មានតម្លៃសូន្យ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ប. ភតិសន្យា (ត)

*ភតិសន្យាក្នុងករណីដែលសាខាធនាគារជាភតិក: (ត)*

សាខាធនាគារ កំណត់អត្រាការប្រាក់កម្ចីកើនឡើងរបស់ខ្លួន ដោយទទួលបានអត្រាការប្រាក់ពីប្រភពហិរញ្ញប្បទានខាងក្រៅផ្សេងៗ និងធ្វើការកែតម្រូវមួយចំនួនដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌនៃភតិសន្យា និងប្រភេទ នៃទ្រព្យសកម្មដែលបានជួល។ សាខាធនាគារប្រើអត្រាការប្រាក់កម្ចីកើនឡើងចាប់ពី 3% - 4% (ឆ្នាំ2021៖ 3% - 4%) ក្នុងមួយឆ្នាំ។

*ភតិសន្យាមានរយៈពេលខ្លី និងភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប*

សាខាធនាគារ បានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ភតិសន្យាលើទ្រព្យសកម្មដែលមានតម្លៃទាប និងភតិសន្យាដែលមានរយៈពេលខ្លី រាប់បញ្ចូលទាំងភតិសន្យាលើគ្រឿងម៉ាស៊ីនផងដែរ។ សាខាធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាទាំងនេះជាការចំណាយលើមូលដ្ឋានរំលស់ថេរទៅតាមរយៈពេលនៃភតិសន្យា។

### ឧ. ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់បញ្ញើរបស់ការិយាល័យកណ្តាល

ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់បញ្ញើរបស់ការិយាល័យកណ្តាលត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការដោយផ្ទាល់ និងវាស់វែងនៅពេលបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### ឍ. ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការដោយផ្ទាល់ និងវាស់វែងនៅពេលបន្ទាប់តាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### ណ. កិច្ចសន្យាធានាហិរញ្ញវត្ថុ និងកិច្ចសន្យាឥណទាន

'ការធានាហិរញ្ញវត្ថុ' គឺជាកិច្ចសន្យាដែលតម្រូវឲ្យសាខាធនាគារធ្វើការទូទាត់ជាក់លាក់ ដើម្បីទូទាត់សងម្ចាស់បំណុលវិញ សម្រាប់ការខាតបង់ដែលបានកើតឡើង ដោយសារតែកូនបំណុលមិនមានលទ្ធភាពទូទាត់សងនៅពេលដែលដល់កាលកំណត់ ដោយស្របតាមលក្ខខណ្ឌនៃឧបករណ៍បំណុល។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ណ. កិច្ចសន្យាធានាហិរញ្ញវត្ថុ និងកិច្ចសន្យាឥណទាន (ត)

'កិច្ចសន្យាឥណទាន' គឺជាកិច្ចសន្យាដែលនឹងត្រូវផ្តល់ឥណទានទៅតាមកាលកំណត់ និងលក្ខខណ្ឌជាក់លាក់ណាមួយ។

ការធានាហិរញ្ញវត្ថុ ដែលបានចេញផ្សាយ ឬជាកិច្ចសន្យាផ្តល់ឥណទាន តាមអត្រាការប្រាក់ក្រោមតម្លៃទីផ្សារត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប។ បន្ទាប់មក ពួកវាត្រូវបានវាស់វែងក្នុងចំនួនដែលខ្ពស់ជាងរវាងសំវិធានធនលើការខាតបង់ ដែលបានកំណត់ដោយអនុលោមតាម ស.រ.ហ.អ.ក 9 (សូមមើលកំណត់សម្គាល់ 38គ(vii)) និងចំនួន ទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ដំបូង ដកប្រាក់ចំណូលបង្គរដែលបានទទួលស្គាល់ដោយអនុលោមតាម ស.រ.ហ.អ.ក 15 ប្រសិនបើសមស្រប។ កិច្ចសន្យាឥណទានផ្សេងៗ ដែលបានបោះផ្សាយត្រូវបានវាស់វែងតាមផលបូកនៃ (i) សំវិធានធនខាតបង់ដែលបានកំណត់ដោយអនុលោមតាម ស.រ.ហ.អ.ក 9 (សូមមើលកំណត់សម្គាល់ 38គ(vii)) និង (ii) ចំនួនទឹកប្រាក់នៃកម្រៃណាមួយដែលទទួលបាន ដកប្រាក់ចំណូលបង្គរដែលត្រូវបានទទួលស្គាល់ (សូមមើលកំណត់សម្គាល់ 38ប) ប្រសិនបើកិច្ចសន្យានេះទំនងជាមានលទ្ធផលនៅក្នុងការរៀបចំការផ្តល់ឥណទានជាក់លាក់នោះទេ។ គោលការណ៍នៃការឈប់ទទួលស្គាល់នៅក្នុងកំណត់សម្គាល់ 38គ(iii)) ត្រូវបានអនុវត្តចំពោះកិច្ចសន្យាឥណទានដែលបានបោះផ្សាយ និងរក្សាទុក។

សាខាធនាគារ ពុំបានបោះផ្សាយកិច្ចសន្យាឥណទាន ដែលត្រូវបានវាស់វែងតាម FVTPL នោះទេ។

បំណុលដែលកើតឡើងពីកិច្ចសន្យាធានាហិរញ្ញវត្ថុ និងកិច្ចសន្យាឥណទាន គឺត្រូវបានរួមបញ្ចូលនៅក្នុងខ្ទង់សំវិធានធន។

### ត. អត្ថប្រយោជន៍និយោជិត

#### *(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើសាខាធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ត. អត្ថប្រយោជន៍និយោជិត (ត)

*(ii). ផែនការវិភាគទានដែលបានកំណត់*

កាតព្វកិច្ចក្នុងការបង់ក្នុងគម្រោងវិភាគទាននេះ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មដែលពាក់ព័ន្ធ ត្រូវបានផ្តល់ឲ្យ និងត្រូវទទួលស្គាល់ជាចំណាយនិយោជិតនៅក្នុងចំណេញ ឬខាត។ វិភាគទានដែលបានបង់ជាមុន ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ក្នុងករណីដែលមានការសងត្រលប់ ឬក៏កាត់បន្ថយសាច់ប្រាក់ទូទាត់នាពេលអនាគត គឺអាចប្រើប្រាស់បាន។

### ថ. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលសាខាធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

### ទ. ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។ ថ្លៃដើមផ្ទាល់ក្នុងការបោះផ្សាយភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធន បន្ទាប់ពីដកពន្ធរួច។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

# ធនាគារ មេយ្ហា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ធ. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានបង្កើតលើភាពខុសគ្នា រវាងសំវិធានធនលើឱនភាព នៃតម្លៃឧបករណ៍ហិរញ្ញវត្ថុ ស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូឆ្នាំ2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ឆ.ណ ចុះថ្ងៃទី 16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ អនុលោមតាម តាមប្រការ 73 គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ 72 និងត្រូវកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ទាបជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់សាខាធនាគារឡើយ។

### ន. ចំណូលការប្រាក់ និងចំណាយការប្រាក់

*(i). អត្រាការប្រាក់ប្រសិទ្ធភាព*

ចំណូលការប្រាក់ និងចំណាយការប្រាក់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានិងទូទាត់ ឬនិងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឲ្យមកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- រំលស់តម្លៃដើមរបស់បំណុលហិរញ្ញវត្ថុ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ន. ចំណូលការប្រាក់ និងចំណាយការប្រាក់ (ត)

*(i). អត្រាការប្រាក់ប្រសិទ្ធភាព (ត)*

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្ម ដែលមានឱនភាពនៃតម្លៃនៅពេលទិញ សាខាធនាគារធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគត ដោយពិចារណាពលក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនៅពេលទិញឬនៅពេលដំបូង អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគត រួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

*(ii). រំលស់ថ្លៃដើម និងតម្លៃយោងដុល*

'រំលស់ថ្លៃដើម' របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់សងប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់ជាលើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវធ្វើនិយ័តភាពចំពោះសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។ "តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ" គឺជារំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក។

*(iii). ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់*

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬរំលស់ថ្លៃដើមនៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ហិរញ្ញវត្ថុដែលមាន អត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្របនៃឧបករណ៍ការពារ នៅកាលបរិច្ឆេទដែលរំលស់ត្រូវបានចាប់ផ្តើមកែតម្រូវ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ន. ចំណូលការប្រាក់ និងចំណាយការប្រាក់ (ត)

*(iii). ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ (ត)*

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើរំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

*(iv). ការបង្ហាញ*

ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម និងការប្រាក់លើឧបករណ៍បំណុលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃលទ្ធផលលម្អិតផ្សេងៗ។

ចំណាយការប្រាក់ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមបញ្ចូលការប្រាក់លើបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមរំលស់ថ្លៃដើម និងបំណុលភតិសន្យា។

### ប. កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត រួមទាំងកម្រៃសេវាគណនីត្រូវបានទទួលស្គាល់នៅពេលសេវាកម្មត្រូវបានបំពេញ។

### 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ប. កម្រៃ និងជើងសា (ត)

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សាខាធនាគារ អាចមានវិសាលភាពដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 9 និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក 15។ ក្នុងករណីនេះ ជាដំបូងសាខាធនាគារត្រូវអនុវត្ត ស.រ.ហ.អ.ក 9 ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក 9 ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក 15 ចំពោះផ្នែក ដែលនៅសេសសល់។

### ផ. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់សាខាធនាគារ ក្រៅពីសន្និធិ ទ្រព្យសកម្មជាប់កិច្ចសន្យា និងពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់ការិយបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ឬទេ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបាន ធ្វើឡើង។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន តម្លៃដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលតែមួយ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅនឹងតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់។

សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ផ្សេងៗ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ជ. ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ការខាតបង់លើឱនភាពនៃតម្លៃនៃឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបែងចែកដោយកាត់បន្ថយតម្លៃយោងនៃមូលនិធិពាណិជ្ជកម្ម របស់ឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ជាមុន ហើយបន្ទាប់មកកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ។

ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់កាលបរិច្ឆេទរាយការណ៍ ថាតើមានសញ្ញាណាណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ស្មានដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឲ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះមិនលើសពីតម្លៃយោងដែលត្រូវកំណត់ (ដករំលស់) ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ។

### ឈ. ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

សាខាធនាគារបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញ រួមបញ្ចូលបំណាកស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយ វាត្រូវបានកត់ត្រាក្រោមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ស.គ.អ.ក 37 *សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្ម យថាភាព* ហើយត្រូវបានទទួលស្គាល់ចំណាយដែលពាក់ព័ន្ធក្នុង "ចំណាយផ្សេងៗ"។

#### *(i). ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ព. ពន្ធលើប្រាក់ចំណេញ (ត)

*(ii). ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានិងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងនូវពន្ធដែលសាខាធនាគាររំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនាកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលពន្ធពន្យារ អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

### ភ. បំណុលយថាភាព

ក្នុងករណីដែលមិនតម្រូវឲ្យមានការហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះកាតព្វកិច្ចមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនោះទេ ហើយវា ត្រូវបានបង្ហាញថាជាបំណុលយថាភាព លើកលែងតែលទ្ធភាពនៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែ អត្ថិភាពនៃកាតព្វកិច្ច នឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ក៏ត្រូវបានបង្ហាញថាជាបំណុលយថាភាពលើកលែងតែលទ្ធភាពនៃការហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើតែគ្មាន។

## 37. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ម. ទ្រព្យសកម្មយថាភាព

ក្នុងករណីដែលមិនមានលទ្ធភាពហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ឬចំនួនទឹកប្រាក់ដែលមិនអាចប៉ាន់ស្មានបាន នោះទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុឡើយ ហើយវាត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាព លើកលែងតែលទ្ធភាពលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចគឺស្ទើតែគ្មាន។ កាតព្វកិច្ចដែលអាចកើតមាន ប៉ុន្តែអត្ថិភាពនៃទ្រព្យសកម្មនឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមួយ ឬច្រើន ត្រូវបានបង្ហាញថាជាទ្រព្យសកម្មយថាភាពលើកលែងតែលទ្ធភាពនៃការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច គឺស្ទើតែគ្មាន។

## 38. ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

សាខាធនាគារ បានអនុវត្តកិច្ចសន្យាខាតបង់ - ចំណាយដើម្បីបំពេញកិច្ចសន្យា (វិសោធនកម្មលើ ស.គ.អ.ក 37) ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2022។ ការអនុវត្តបែបនេះ បណ្តាលឲ្យមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ សម្រាប់ការអនុវត្តការវាយតម្លៃកិច្ចសន្យាខាតបង់។ កាលពីមុន សាខាធនាគាររួមបញ្ចូលតែចំណាយបន្ថែមដើម្បីបំពេញកិច្ចសន្យាប៉ុណ្ណោះ នៅពេលកំណត់ថាតើកិច្ចសន្យានោះជាកិច្ចសន្យាខាតបង់។ គោលនយោបាយដែលបានកែសម្រួលគឺរួមបញ្ចូលទាំងចំណាយបន្ថែម និងការបែងចែកចំណាយផ្ទាល់ផ្សេងៗទៀត។

សាខាធនាគារ បានធ្វើការវិភាគរាល់កិច្ចសន្យាទាំងអស់ដែលមាន នាថ្ងៃទី1 ខែមករា ឆ្នាំ2022 ហើយបានកំណត់ថា ពុំមានកិច្ចសន្យាណាមួយក្នុងចំណោមកិច្ចសន្យាទាំងនោះមានការខាតបង់ និងត្រូវអនុវត្តតាមគោលនយោបាយគណនេយ្យដែលបានកែសម្រួលឡើងវិញនោះទេ ពោលគឺមិនមានផលប៉ះពាល់លើសមតុល្យមូលធនដើមគ្រានៅថ្ងៃទី1 ខែមករា ឆ្នាំ2022 ដែលជាលទ្ធផលនៃការផ្លាស់ប្តូរនោះឡើយ។

## 39. ស្តង់ដាថ្មី វិសោធនកម្ម និងការបកស្រាយថ្មី ដែលមិនទាន់បានអនុវត្ត

ស្តង់ដាថ្មី វិសោធនកម្ម និងការបកស្រាយថ្មីមួយចំនួន ទាក់ទងនឹងស្តង់ដាដែលមានស្រាប់បានចូលជាធរមាន សម្រាប់ការិយបរិច្ឆេទចាប់ផ្តើមបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2022 ដែលការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត។ យ៉ាងណាមិញ សាខាធនាគារមិនទាន់បានអនុវត្តនូវស្តង់ដាថ្មី ឬស្តង់ដាដែលបានធ្វើវិសោធនកម្មទាំងនេះក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះនៅឡើយទេ។

## 39. ស្តង់ដាថ្មី វិសោធនកម្ម និងការបកស្រាយថ្មី ដែលមិនទាន់បានអនុវត្ត (ត)

ស្តង់ដា និងការបកស្រាយដែលបានធ្វើវិសោធនកម្មដូចខាងក្រោមមិនត្រូវបានរំពឹងថានឹងមានផលប៉ះពាល់គួរឲ្យកត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនោះទេ៖

- ការលាតត្រដាងព័ត៌មានលើគោលនយោបាយគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក 1 និងសេចក្តីថ្លែងការណ៍ការអនុវត្ត ស.រ.ទ.ហ.អ.ក លើកទី2)
- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក 8)
- ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុល ដែលកើតឡើងពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ ស.គ.អ.ក 12)
- ចំណាត់ថ្នាក់បំណុលដែលជាបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង (វិសោធនកម្មលើស.គ.អ.ក 1) និង
- បំណុលភតិសន្យាក្នុងការលក់ និងជួលត្រឡប់មកវិញ (វិសោធនកម្មលើ ស.រ.ទ.ហ.អ.ក)។